Raksmey Kampuchea Daily, Thursday 12th June 2014 (Page 2D)

# ជនជាតិជប៉ុនចាត់ទុករបៀបតុបតែងផ្កាដូចជាឪពុកម្តាយរបស់ពួកគេ




*អ្នកចូលរួមក្នុងពិធីបង្ហាញពីវប្បធម៌តុបតែងផ្កា របស់ជនជាតិជប៉ុន (រូបថត:មេសា)*




*ឯកអគ្គរាជទូតជប៉ុន លោក យុជិ គុម៉ាម៉ារុ ថ្លែងបើក-ពិធីបង្ហាញរបៀបតុបតែងផ្កា របស់ជនជាតិជប៉ុន*

**ភ្នំពេញ :** សាស្ត្រាចារ្យនៅវិទ្យាស្ថាន បច្ចេកវិជ្ជាធម្មជាតិ និងបរិស្ថាននៃសកលវិទ្យាល័យ Kanazawa ប្រទេសជប៉ុន លោកបណ្ឌិត Shinji Tsukawaki បានថ្លែងថា " ឆ្លងកាត់ប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំប្រជាជនជប៉ុនបានចាត់ទុក របៀបតុបតែងផ្កា (Ikebana) ដូចជា ឪពុក និងម្តាយរបស់ខ្លួន " ។

លោកបណ្ឌិតលើកឡើងដូច្នេះ ក្នុងពេលលោកធ្វើបទបង្ហាញអំពីរបៀបតុបតែងផ្កា (Ikebana) របស់ជនជាតិជប៉ុនរៀបចំដោយស្ថានទូតជប៉ុនប្រចាំកម្ពុជា កាលពីរសៀល ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ នៅស្ថានទូតជប៉ុន ក្រោមអធិបតីភាពឯកអគ្គរាជទូតជប៉ុន លោក យុជិ គុម៉ាម៉ារុ ដោយមានការអញ្ជើញចូលរួមពីសំណាក់ភ្ញៀវភាគច្រើនជាស្ត្រីដែលជាប្រតិភូរបស់-សមាគមស្ត្រីអាស៊ី (AWC) ប្រមាណជាជិត១០០នាក់ ។

លោកបណ្ឌិត Shinji Tsukawaki បានបន្ថែមទៀតថា របៀបតុបតែងផ្ការបស់ជនជាតិជប៉ុនមានចំនួនជាង-៣០០ប្រភេទ ហើយបច្ចុប្បន្ននៅប្រទេសជប៉ុនមានសាលាបង្រៀនពីរបៀបតុបតែងផ្កាជាង៣០០សាលា ។

ឯកអគ្គរាជទូតជប៉ុន លោក យុជិ គុម៉ាម៉ារុ បានរំលឹកយ៉ាងសង្ខេបអំពីសារៈសំខាន់នៃរបៀបតុបតែងផ្កានៅប្រទេសជប៉ុនថា ត្រូវបានគេជឿថា របៀបតុបតែងផ្កាជាលក្ខណៈប្រពៃណីបានប្រសូត្រចេញពីសង្គមពុទ្ធសាសនិក លុះក្រោយមកក៏ត្រូវបានពួកអភិជនយកទៅប្រើប្រាស់ក្នុងជីវភាពរបស់ពួកគេ ។ ពេលវេលាកន្លងទៅរាប់ពាន់ឆ្នាំ របៀបតុបតែងផ្កាដ៏សម្បូរបែបនេះ ក៏បានក្លាយជាសិល្បៈប្រចាំថ្ងៃនៃជនជប៉ុនទូទៅ ហើយមិនមែននៅតែក្នុងប្រទេសជប៉ុនប៉ុណ្ណោះទេ គឺរីកសាយសម្រាប់មនុស្សទូទាំងពិភពលោក ។

ប្រធានសមាគមស្ត្រីអាស៊ី លោកស្រី រស់ ស៊ីម៉ាវ៉ា ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រីហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានលើកឡើងថា ស្ត្រីប្រៀបដូចជាផ្កា ។ ស្ត្រីអាចធ្វើឱ្យបុរសរីករាយ និងមានសុភមង្គល ហើយនោះគឺជាមូលហេតុដែលមនុស្សគ្រប់រូប ជាពិសេសបុរសត្រូវតែថែស្ត្រីឱ្យបានល្អដូចជាផ្កា ៕

**មេសា**